ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តក្រចេះ

~~~~~

សំណុំរឿងរដ្ឋប្បវេណី

លេខ ៧៣ ចុះថ្ងៃទី ០៧

ខែ កញ្ញា ឆ្នាំ ២០១០

សាលក្រមលេខ ០៨(ត)

ចុះថ្ងៃទី ២៩.១០.២០១០

## ក្នុងនាមប្រជារាស្ត្រខ្មែរ

សាលាដំបូងខេត្តក្រចេះបានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់នៅថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ២០១០ ដោយមានសមាសភាពជំនុំជំរះដូចតទៅ :

## ចៅក្រមជំនុំជំរះ

លោក [redacted] ចៅក្រមសាលាដំបូងខេត្ត

## ក្រឡាបញ្ជីសវនាការ

លោកស្រី [redacted] ក្រឡាបញ្ជីសាលាដំបូងខេត្ត

-ដើមចោទឈ្មោះ [redacted] សុផារ៉ុម (ជុំ សុផារ៉ុម ហៅ ស៊ីយ៉េត) ភេទស្រី អាយុ៤៧ឆ្នាំ ជាតិខ្មែរ មានទីលំនៅភូមិក្បាលកោះ សង្កាត់កោះទ្រង់ ក្រុងក្រចេះ ខេត្តក្រចេះ។

-ចុងចំលើយឈ្មោះ [redacted] រិទ្ធី ភេទប្រុស អាយុ៣៨ឆ្នាំ មានទីលំនៅភូមិក្បាលកោះ សង្កាត់កោះទ្រង់ ក្រុងក្រចេះ ខេត្តក្រចេះ។

## អង្គហេតុ និង ចំណុចវិវាទ

**ក-សាលក្រមដែលទាមទារដោយដើមចោទ :**

-សុំបដិសេធលក្ខិកៈផ្ទេរមរតក ចុះថ្ងៃទី ២២.០១.២០០៣។

-សុំគ្រប់គ្រងដីភូមិក្បាល៩ម បណ្ដោយ២៨០ម និង ផ្ទះទំហំ៩.៧ម បណ្ដោយ ១២ម ស្ថិតនៅភូមិក្បាលកោះ សង្កាត់កោះទ្រង់ ក្រុងក្រចេះ ខេត្តក្រចេះ។

-សុំអោយចុងចម្លើយរ៉ាប់រងប្រាក់ប្រដាប់ក្ដី។

**ខ-សាលក្រមទាមទារដោយចុងចម្លើយ :**

-សុំបដិសេធការទាមទាររបស់ដើមចោទ

**គ-អំពីដំណើររឿងក្ដី :**

ដើមចោទឈ្មោះ [redacted] សុផារ៉ុម ថ្លែងការណ៍ថា : ខ្លួនទាមទារដូចខាងលើដោយសំអាងថា : ដី និង ផ្ទះនេះជាមរតករបស់ម្ដាយខ្លួនឈ្មោះ [redacted] រិន ខ្លួនបានកាន់កាប់រស់នៅជួសជុលផ្ទះតាំងពីឆ្នាំ១៩៧៩រហូតទល់សព្វថ្ងៃហើយម្ដាយខ្លួន និង បងស្រីពិការឈ្មោះ [redacted] សារ៉ាត់ រស់នៅផ្ទះដីនេះក្នុងបន្ទុករបស់ខ្លួនដោយខ្លួនជាមេគ្រួសារ ប៉ុន្តែនៅឆ្នាំ២០០១ខ្លួនទៅធ្វើការនៅភ្នំពេញកូនស្រីខ្លួនឈ្មោះ [redacted] ធីតា(ហ ស៊ូរីតា) រស់នៅជាប់លាប់ជាមួយម្ដាយឈ្មោះ [redacted] រិន និង បងស្រីពិក [redacted] សារ៉ាត់ រហូតម្ដាយខ្លួនស្លាប់ឆ្នាំ២០០៣ បងស្រីស្លាប់ថ្ងៃទី ១៣.៨.២០១០។
~~~~~

រយៈពេលខ្លួនទៅធ្វើការនៅភ្នំពេញខ្លួនទៅមកថែរក្សាម្តាយជាធម្មតា ឯម្តាយចុងចម្លើយស្លាប់ឆ្នាំ២០០៣ និង ចុងចម្លើយពុំដែលរស់នៅផ្ទះនិងដីនេះទេ ខ្លួនមានសៀវភៅគ្រួសារចុះថ្ងៃទី០៨.០២.១៩៩៩។ ចំពោះលិខិតផ្ទេរដី.ផ្ទះចុះថ្ងៃទី២២.០១.២០០៣របស់ចុងចម្លើយខ្លួនសុំបដិសេធដោយសំអាងថា លិខិតនេះធ្វើឡើងពុំត្រឹមត្រូវ ខ្លួនពុំបានដឹង ហើយធ្វើពេលម្តាយខ្លួនកំពុងឈឺធ្ងន់។

-ចុងចម្លើយឈ្មោះ [redacted] រិទ្ធី ថ្លែងការណ៍ថា: ខ្លួនពុំទទួលស្គាល់ការទាមរបស់ដើមចោទទេ ដោយសំអាងថា : ដី.ផ្ទះនេះដើមឡើយជីដូនខ្លួនឈ្មោះ [redacted] រិន(គីម រិន) ជីតា [redacted] ចេង រស់នៅជាមួយកូន១ទៅលើវ បន្ទាប់ពីកូន១មានគ្រួសារបែកចេញអស់មានតែម្តាយមីងពិកាឈ្មោះ [redacted] សារ៉ាត់ រស់នៅអចិន្ត្រៃយ៍ជាមួយជីដូន [redacted] រិន (ជីដូនស្លាប់ឆ្នាំ២០០៣) ម្តាយមីងទើបស្លាប់ថ្ងៃទី១៣.០៨.២០១០ ហើយដី.ផ្ទះនេះជីដូនឈ្មោះ [redacted] រិន បានផ្ទេរអោយម្តាយខ្លួនឈ្មោះ [redacted] (ស្លាប់ចុងឆ្នាំ២០០៣) តាមលក្ខន្តិកៈផ្ទេរមត៌កចុះថ្ងៃទី២២.០១.២០០៣ ម្តាយខ្លួនរស់នៅផ្ទះជាប់គ្នានេះតែបានគ្រប់គ្រងផ្ទះ.ដីនេះរហូតគាត់ស្លាប់ នៅម្តាយមីងពិការរស់នៅបន្តរហូតស្លាប់ ចំណែកខ្លួនបួសជាសង្ឃនៅភ្នំពេញ បច្ចុប្បន្នក្រោយពីម្តាយមីងឈ្មោះ [redacted] សារ៉ាត់ ស្លាប់បងប្អូនឈ្មោះ [redacted] តាត.កៅសុគន្ធា.[redacted] ចន្ទីន. [redacted] តាយ [redacted] តេង. [redacted] តៃ [redacted] សុវណ្ណនី. ឪពុកខ្លួន [redacted] គុន បានឯកភាពប្រគល់ផ្ទះ.ដីនេះអោយរូបខ្លួនគ្រប់គ្រងបន្ត ទំហំដីមានតែក្បាល៩ម បណ្តោយ ២១០ម។

**ឃ-ចំណុចវិវាទ :**

-ដើមចោទសុំបដិសេធលក្ខន្តិកៈផ្ទេរមរតកចុះថ្ងៃទី២២.០១.២០០៣ និង សុំគ្រប់គ្រងដីភូមិក្បាល៩ម បណ្តោយ២៨០ម និង ផ្ទះទំហំ៩.៧ម បណ្តោយ១២ម ស្ថិតនៅភូមិក្បាលកោះ សង្កាត់កោះទ្រង់ ក្រុងក្រចេះ ខេត្តក្រចេះ។

-ចុងចម្លើយបដិសេធការទាមទាររបស់ដើមចោទ ។

**ង-ការដាក់ភស្តុតាង :**

-ដើមចោទដាក់ភស្តុតាងឯកសារមាន :

-បញ្ជីគ្រួសារ ចុះថ្ងៃទី០៨.០២.១៩៩៩ ចំនួន០១ច្បាប់

-លិខិតបញ្ជាក់របស់នាយប៉ុស្តិ៍ សង្កាត់កោះទ្រង់ ចំនួន០១ច្បាប់

-កំណត់ហេតុរបស់ចៅសង្កាត់កោះទ្រង់ចំនួន០១ច្បាប់

-ភស្តុតាងសាក្សីចំនួន៤នាក់ គឺឈ្មោះ [redacted] សារីម. ចែ [redacted] ស្រី. [redacted] ឡឿន. និង ឈ្មោះ [redacted] សើរ។

-ចុងចម្លើយដាក់ភស្តុតាងឯកសារ :

- លក្ខន្តិកៈផ្ទេរមរតក ចុះថ្ងៃទី២២.០១.២០០៣ ចំនួន០១ច្បាប់

-លិខិតផ្ទេរសិទ្ធិកាន់កាប់អចលនវត្ថុ ចុះថ្ងៃទី០១.០៨.២០១០ចំនួន០១ច្បាប់

-ពាក្យសុំកាន់កាប់ដីធ្លីចុះថ្ងៃទី១៩.៨.២០១០ចំនួន០១ច្បាប់

-ភស្តុតាងសាក្សី៥នាក់គឺ : ឈ្មោះ [redacted] គិត. [redacted] រឿន. [redacted] សារ៉ុត. [redacted] ស៊ីយ៉ុត និង ឈ្មោះ [redacted] ស៊ីយិន។

៤៩១

Scanned with CamScanner

## សំអាងហេតុ

-ដើមចោទឈ្មោះ[redacted]សុផារ៉ុម បានអះអាងថា ដីទំហំ ក្បាល៩ម បណ្ដោយ២៨០ម និង ផ្ទះទំហំ៩.៧ម បណ្ដោយ១២ម សង់ពីឈើប្រក់ក្បឿង៣ខ្នង ជាកេរ្ដិ៍មរតកម្ដាយឈ្មោះ[redacted]រិន(ស្លាប់ឆ្នាំ២០០៣) ខ្លួនបានកាន់កាប់រស់នៅជួសជុលផ្ទះពីឆ្នាំ១៩៧៩រហូតមកទល់សព្វថ្ងៃ ដោយម្ដាយខ្លួន និង បងស្រីខ្លួនឈ្មោះ[redacted]សារ៉ាត់ រស់នៅក្នុងបន្ទុករបស់ខ្លួនដូចមានក្នុងសៀវភៅស្នាក់នៅចុះថ្ងៃទី ០៨.០២.១៩៩៩ ប៉ុន្តែនៅឆ្នាំ២០០១ខ្លួនទៅធ្វើការនៅភ្នំពេញ កូនស្រីខ្លួនឈ្មោះ[redacted] ធីតា[redacted]សូរីតា) រស់នៅជាប់លាប់ជាមួយជីដូន[redacted]រិន និង បងស្រីពិក[redacted]សារ៉ាត់ ខ្លួនទៅមកធម្មតា ចុងចម្លើយពុំដែលរស់នៅផ្ទះ.ដីនេះទេ ហើយលិខិតលក្ខន្តិកៈផ្ទេរមរតកចុះថ្ងៃទី២២.០១.២០០៣ ធ្វើពុំត្រឹមត្រូវ ពេលធ្វើខ្លួនពុំបានដឹង ធ្វើពេលម្ដាយខ្លួនឈឺធ្ងន់។

-ចុងចម្លើយឈ្មោះ[redacted] វិទ្ធី អះអាងថា: ខ្លួនពុំទទួលស្គាល់តាមការទាមរបស់ដើមចោទដោយសំអាងថា: ដីទំហំក្បាល៩ម បណ្ដោយមានតែ២១០ម និង ផ្ទះ ជាកេរ្ដិ៍មរតកជីដូនឈ្មោះ[redacted] រិន([redacted] រិន) ស្លាប់ឆ្នាំ២០០៣ និង ជីតា ឈ្មោះ[redacted]ចេង(ស្លាប់) រស់នៅពីឆ្នាំ១៩៧៩ជាមួយកូន១នៅលីវរហូតមកដល់កូនមានគ្រួសារបែកចេញអស់ ជីដូន ឈ្មោះ[redacted]រិន រស់នៅជាមួយម្ដាយមីងពិកាឈ្មោះ[redacted]សារ៉ាត់ ថ្ងៃទី២២.០១.២០០៣ ជីដូនឈ្មោះ [redacted] រិន [redacted] រិន) ផ្ទេរដី.ផ្ទះនេះអោយម្ដាយខ្លួនឈ្មោះ[redacted] រី(ស្លាប់ចុងឆ្នាំ២០០៣) ម្ដាយមីងពិការស់នៅបន្តរហូតស្លាប់ថ្ងៃទី១៣.៨.២០១០ ឯខ្លួនបួសជាសង្ឃនៅភ្នំពេញ ក្រោយពីម្ដាយខ្លួនស្លាប់បងប្អូនបានផ្ទេរដី.ផ្ទះ នេះអោយខ្លួន។

-តាមភស្តុតាងឯកសារដើមចោទ សៀវភៅស្នាក់នៅ(ក.១) ចុះថ្ងៃទ ០៨.០២.១៩៩៩ គឺឈ្មោះ[redacted] សុផារ៉ុម ហៅ ស៊ីយ៉េត ជាមេគ្រួសារដែលមានសមាជិកក្នុងបន្ទុកឈ្មោះ [redacted]សុផា(កូន)[redacted]គុណវត្ត (កូន). ហសូរីតា(កូន)[redacted]រិន(ម្ដាយបង្កើត)[redacted]សារ៉ាត់(បង) និង លិខិតបញ្ជាក់របស់នាយប៉ុស្តិ៍នគរបាលរដ្ឋបាលសង្កាត់កោះទ្រង់លេខ៩១ចុះថ្ងៃទី២៣.០៩.២០១០ថា ឈ្មោះ[redacted] សុផារ៉ុម ហៅ ស៊ីយ៉េត ភេទស្រី អាយុ៤៧ឆ្នាំ ជាមេគ្រួសារស្នាក់នៅផ្ទះលេខ១២៨ មានសមាជិក៥នាក់ពិតប្រាកដមែន។

-តាមការអះអាងរបស់ដើមចោទ. ចុងចម្លើយ. សាក្សីដើមចោទ. សាក្សីចុងចម្លើយ និង ការពិនិត្យភស្តុតាងឯកសារឃើញថា : ដើមចោទបានកាន់កាប់រស់នៅលើផ្ទះ.ដីទំនាស់នេះពីឆ្នាំ១៩៧៩ជាប់លាប់រហូតមក និង ជាមេគ្រួសារមានម្ដាយឈ្មោះ [redacted]រិន.បងស្រីពិកាឈ្មោះ [redacted]សារ៉ាត់ និង កូន១ដើមចោទរស់នៅក្នុងបន្ទុកមានសៀវភៅគ្រួសារ(ក.១)ចុះថ្ងៃទី០៨.០២.១៩៩៩ ទទួលស្គាល់ពីរដ្ឋអំណាចត្រឹមត្រូវតាមច្បាប់ បន្ទាប់ពីដើមចោទទៅធ្វើការនៅភ្នំពេញនៅឆ្នាំ២០០១ ដើមចោទទៅមក និង កូនដើមចោទឈ្មោះ[redacted]ធីតា រស់នៅផ្ទះ.ដីជាប់លាប់ជាមួយជីដូន[redacted] រិន(ស្លាប់ឆ្នាំ២០០៣) និង ម្ដាយមីងពិកាឈ្មោះជុំ សារ៉ាត់(ស្លាប់ថ្ងៃទី១៣.៨.២០១០) ឯចុងចម្លើយបួសជាសង្ឃនៅភ្នំពេញពុំដែលរស់នៅលើផ្ទះ.ដីទំនាស់នេះទេ។ប៉ុន្តែចុងចម្លើយបានទទួលសិទ្ធិបន្តមរតកពីម្ដាយឈ្មោះ [redacted] រី តាមលក្ខន្តិកៈផ្ទេរមរតកចុះថ្ងៃទី២២.០១.២០០៣ និង ទទួលសិទ្ធិពីឪពុកឈ្មោះ [redacted] គុន តាមលិខិតផ្ទេរសិទ្ធិចុះថ្ងៃទី០១.០៨.២០១០ដោយមានមេភូមិ.ចៅសង្កាត់ចូលរួមផងដែរ។ ផ្អែកលើការអះអាងនេះ

តុលាការពិនិត្យពិចារណាអំពីសិទ្ធិកាន់កាប់ ព្រមទាំងការទំនាក់ទំនងរស់នៅ និង អាទិភាព របស់ភាគីដែលត្រូវបន្តមរតកដី.ផ្ទះនេះអោយបានសមស្របតាមនីតិវិធី។ ម្យ៉ាងទៀតតាមលិខិតបញ្ជាក់របស់មេភូមិក្បាលកោះ [redacted] យេន ចុះថ្ងៃទី១៤.១០.២០១០ថា ឈ្មោះ [redacted] រិន ស្លាប់ថ្ងៃទី២៦.០១.២០០៣ ម៉ោង៥.៣០នាទីល្ងាច ឯលក្ខន្តិកៈផ្ទេរមរតកដី.ផ្ទះធ្វើនៅថ្ងៃទី២២.០១.២០០៣មុន [redacted] រិន ស្លាប់៤ថ្ងៃ និង ដើមចោទព្រមទាំងកូនរបស់សពដទៃទៀតពុំបានចូលរួមដឹងឮ គប្បីតុលាការពិចារណាលើបញ្ហានេះ។

**សេចក្តីសំរេចបញ្ចប់ :**

១-បដិសេធលក្ខន្តិកៈផ្ទេរមរតក ចុះថ្ងៃទី២២.០១.២០០៣ ចោលជាអសាបង់។

២-ទទួលស្គាល់ការទាមទាររបស់ដើមចោទពីសិទ្ធិគ្រប់គ្រងដីទំហំ ក្បាល៩ម៉ែត្រ បណ្តោយ២៨០ម៉ែត្រ និង ផ្ទះក្បឿង៣ខ្នងសង់ពីឈើលើដីនេះ ទំហំ៩.៧ម៉ែត្រ បណ្តោយ១២ម៉ែត្រ មានទីតាំងស្ថិតនៅភូមិក្បាលកោះ សង្កាត់កោះទ្រង់ ក្រុងក្រចេះ ខេត្តក្រចេះ មានព្រំប្រទល់: ខាងជើងជាប់ឈ្មោះ [redacted] ស៊ីយ៉ូត . ខាងត្បូងជាប់ ជុំ សារ៉េត. ខាងលិចជាប់ទន្លេមេគង្គ .ខាងកើតជាប់ [redacted] ទឹម ព្រមទាំងប្រគល់ដី និង ផ្ទះនេះអោយដើមចោទឈ្មោះ [redacted] សុផារ៉ុម គ្រប់គ្រងកាន់កាប់ចាប់ពីថ្ងៃសាលក្រមនេះចូលជាស្ថាពរ។

៣-ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ចុងចម្លើយ។

៤-សាលក្រមនេះ ទាញហេតុផលដោយផ្ទាល់មាត់ចំពោះមុខគូភាគី និង ប្រកាសជាសាធារណៈនៅថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ២០១០។

បើកផ្លូវប្តឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់។

**ចៅក្រមជំនុំជំរះ**

**ហត្ថលេខា និង** [redacted]

---

**បានឃើញ**

ក្រចេះ ថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ២០១០

**ចៅក្រមជំនុំជំរះ**

[redacted]

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

ក្រចេះ ថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ២០១០

**ក្រឡាបញ្ជី**

[redacted]